ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ២២៥ "ព" ក្រ៣

ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤

-សំណុំរឿងព្រហ្មទណ្ឌលេខ៣៧០៦

ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣

-សំណុំរឿងស៊ើបសួរលេខ ៣១៧៩

ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

-សំណុំរឿងជំនុំជម្រះលេខ ៤៧២៧

ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការអសាធារណៈ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង០៨ និង៣០នាទី នៅសាលសវនាការទី៣ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧០៦ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ (កើតថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៧) ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៨ថ្មី មុខរបរដឹកអេតចាយ ឪពុកឈ្មោះ [redacted] សុខចំរើន "ស្លាប់" ម្តាយឈ្មោះ [redacted] វន "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន ទីកន្លែងកំណើត: [redacted] ខេត្តកំពង់ស្ពឺ។ អាសយដ្ឋានបច្ចុប្បន្ន: ស្នាក់នៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៤៩៧ "ង" ង.ឃ.ង ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ ។ (PJ)

២.ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ថ្នាក់ទី៧ថ្មី មុខរបរកម្មករ ឪពុកឈ្មោះ [redacted] សោម "រស់" ម្តាយឈ្មោះ [redacted] មុំ "រស់" នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ ទីកន្លែងកំណើត: ភូមិ [redacted] រាជធានីភ្នំពេញ។ អាសយដ្ឋានបច្ចុប្បន្ន: ស្នាក់នៅបន្ទប់ជួលគ្មានលេខ ផ្លូវលំ ភូមិសន្សំកុសល១ សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៤៩៦ "ង" ង.ឃ.ង ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣។ (PJ)



Scanned with CamScanner

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចខាងកើតស្ពានអាកាស ផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គន្ធា ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅភូមិសំបួរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

ជនរងគ្រោះឈ្មោះ [redacted] កំសាន ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅភូមិសំបួរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង២០ និង០០នាទី នៅចំណុចខាងកើតស្ពានអាកាសផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ, ឈ្មោះ លី ភេទប្រុស អាយុ១៨ឆ្នាំ និងបក្ខពួកចំនួន០៣នាក់ទៀត បានរួមគ្នាធ្វើសកម្មភាពឆក់ម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] កំសាន ភេទប្រុស អាយុ៣៧ឆ្នាំ និងបានដោះមួកសុវត្ថិភាពវាយជនរងគ្រោះបណ្តាលឱ្យរងរបួស រួចយកម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម សេ១២៥ ស៊េរីឆ្នាំ២០២៣ ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1KC-7815 បានសម្រេច ហើយនាំគ្នាជិះគេចខ្លួនបាត់ទៅ ភ្លាមៗនោះប្រពន្ធរបស់ជនរងគ្រោះ ក៏បានដាក់ពាក្យបណ្តឹងនៅអធិការដ្ឋាននគរបាលខណ្ឌដង្កោ ដើម្បីស្រាវជ្រាវចាប់ខ្លួនជនជាប់ចោទ លុះដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ សមត្ថកិច្ចនៃអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] ហេង និងឈ្មោះ [redacted] ចាន់លាប ក្នុងករណីផ្សេង បន្ទាប់មកសមត្ថកិច្ចនៃអធិការដ្ឋាននគរបាលខណ្ឌដង្កោ ក៏បានទៅធ្វើការសាកសួរក្នុងករណីបទល្មើសកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ នេះតែម្តង។ ចំណែកឈ្មោះ លី ភេទប្រុស និងបក្ខពួកចំនួន០៣នាក់ទៀត បានរត់គេចខ្លួនបាត់ រួចសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

-បានឃើញ របាយការណ៍សំយោគលេខ ០៦០/២៣ រ.ប.ក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៨៤ អ.យ.ឃ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨៣៧ "ង" ង.ង ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ [redacted] ហេង បានរង់ចាំឈ្មោះ លី និងបក្ខពួក នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន ស្ថិតនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ២ ដើម្បីប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋដែលជិះតាមផ្លូវ។ បន្តិចក្រោយមកឈ្មោះ លី និងបក្ខពួកបានមកដល់ តែខ្លួនស្គាល់តែឈ្មោះ លី តែម្នាក់ប៉ុណ្ណោះ។ ឈ្មោះ លី និងបក្ខពួក មានគ្នា០៥នាក់ សុទ្ធតែមនុស្សប្រុស បានជិះម៉ូតូចំនួន០៣គ្រឿង បន្ទាប់មកឈ្មោះ លី ក៏បានឱ្យម៉ូតូទៅឈ្មោះ [redacted] ហេង ជាអ្នកបើក ចំណែកខ្លួនជាអ្នកជិះពីក្រោយ ហើយពួកខ្លួនក៏បានជិះម៉ូតូតាមផ្លូវក្រវ៉ាត់ក្រុងទី៣ ខាងកើតស្ពានអាកាស ដែលស្ថិតនៅក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ ក៏បានឃើញបុរសម្នាក់ជិះម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125 លេខតួ និងលេខម៉ាស៊ីន 001807 ស៊េរីឆ្នាំ២០២៣ មានផ្លាក



Scanned with CamScanner

លេខភ្នំពេញ 1KC-7815 កំពុងធ្វើដំណើរទិសដៅពីខាងកើតទៅខាងលិច ពេលនោះឈ្មោះ លី និងបក្ខពួកចំនួន០៥នាក់ បានជិះម៉ូតូពីរគ្រឿង ទៅស្ទាក់ពីមុខ និងធាក់ផ្តួលម៉ូតូនោះតែម្តង ចំណែករូបខ្លួនដែលជិះម៉ូតូជាមួយឈ្មោះ មុត ហេង ជាអ្នកចាំស្ទាក់ពីក្រោយ បន្ទាប់មកក្រុមរបស់ឈ្មោះ លី ក៏បានយកម្ជុកការពារវាយលើបុរសនោះ រហូតដល់ក្រោកលែងរួច ហើយក៏លើកម៉ូតូនោះជិះទៅត្រង់ទិសដៅខាងលិច ចំណែករូបខ្លួន និងឈ្មោះ [redacted] ហេង ក៏បានបើកម៉ូតូត្រឡប់ក្រោយ ហើយជិះទៅចាំពួកគាត់នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ ឈ្មោះ លី បានជិះម៉ូតូ០១គ្រឿង ជាមួយនឹងគ្នាគាត់ម្នាក់ទៀតមកយកប្រាក់ឱ្យខ្លួនចំនួន ៨០.០០០(ប្រាំបីម៉ឺន)រៀល ចំណែកឈ្មោះ មុត ហេង គាត់មិនទាន់បានប្រាក់នោះទេ។ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ មុតហេង រួមទាំងបក្ខពួករបស់ឈ្មោះ លី មានម៉ូតូចំនួន០៣គ្រឿង បានជិះម៉ូតូ បំណងប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋ លុះមកដល់ចំណុចផ្លូវបេតុង ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ក៏ត្រូវបានសមត្ថកិច្ចឃាត់បានរូបខ្លួន និងឈ្មោះ [redacted] ហេង ទៅអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ ដើម្បីសួរនាំតែម្តង ចំណែកបក្ខពួករបស់ឈ្មោះ លី បានជិះម៉ូតូគេចខ្លួនបាត់។

ជនជាប់ចោទឈ្មោះ [redacted] ហេង បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ[redacted] ចាន់លាប បានរង់ចាំឈ្មោះ លី និងបក្ខពួក នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន ស្ថិតនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ២ ដើម្បីប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋដែលជិះតាមផ្លូវ។ បន្តិចក្រោយមកឈ្មោះ លី និងបក្ខពួកបានមកដល់ តែខ្លួនស្គាល់តែឈ្មោះ លី តែម្នាក់ប៉ុណ្ណោះ។ ឈ្មោះ លី និងបក្ខពួក មានគ្នា០៥នាក់ សុទ្ធតែមនុស្សប្រុស បានជិះម៉ូតូចំនួន០៣គ្រឿង បន្ទាប់មកឈ្មោះ លី ក៏បានឱ្យម៉ូតូមកខ្លួនជាអ្នកបើក ចំណែកឈ្មោះ [redacted] ចាន់លាប ជាអ្នកជិះពីក្រោយ ហើយពួកខ្លួនក៏បានជិះម៉ូតូតាមផ្លូវក្រវ៉ាត់ក្រុងទី៣ ខាងកើតស្ពានអាកាស ដែលស្ថិតនៅក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ ក៏បានឃើញបុរសម្នាក់ជិះម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125 លេខតួ និងលេខម៉ាស៊ីន 001807 ស៊េរីឆ្នាំ២០២៣ មានផ្លាកលេខភ្នំពេញ 1KC-7815 កំពុងធ្វើដំណើរទិសដៅពីខាងកើតទៅខាងលិច ពេលនោះឈ្មោះ លី និងបក្ខពួកចំនួន០៥នាក់ បានជិះម៉ូតូពីរគ្រឿង ទៅស្ទាក់ពីមុខ និងធាក់ផ្តួលម៉ូតូនោះតែម្តង ចំណែករូបខ្លួនដែលជិះម៉ូតូជាមួយឈ្មោះ [redacted] ចាន់លាប ជាអ្នកចាំស្ទាក់ពីក្រោយ បន្ទាប់មកក្រុមរបស់ឈ្មោះ លី ក៏បានយកម្ជុកការពារវាយលើបុរសនោះ រហូតដល់ក្រោកលែងរួច ហើយក៏លើកម៉ូតូនោះជិះទៅត្រង់ទិសដៅខាងលិច ចំណែករូបខ្លួន និងឈ្មោះ [redacted] ចាន់លាប ក៏បានបើកម៉ូតូត្រឡប់ក្រោយ ហើយជិះទៅចាំពួកគាត់នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ ឈ្មោះ លី បានជិះម៉ូតូ០១គ្រឿង ជាមួយនឹងគ្នាគាត់ម្នាក់ទៀត បានឱ្យប្រាក់ទៅឈ្មោះ [redacted] ចាន់លាប ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) រៀល ចំណែកខ្លួនគាត់ថាចាំពេលក្រោយ។ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ[redacted] ចាន់លាប រួមទាំងបក្ខពួករបស់ឈ្មោះ លី មានម៉ូតូចំនួន០៣គ្រឿង បានជិះម៉ូតូ បំណងប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋ លុះមកដល់ចំណុចផ្លូវបេតុង ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ក៏ត្រូវបានសមត្ថកិច្ចឃាត់បានរូបខ្លួន និងឈ្មោះ[redacted] ចាន់លាប ទៅអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យដើម្បីសួរនាំតែម្តង ចំណែកបក្ខពួករបស់ឈ្មោះ លី បានជិះម៉ូតូគេចខ្លួនបាត់។

ក្រឡាបញ្ជីអានកំណត់ហេតុបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] គន្ធា បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងតំណាងអយ្យការប្រហាក់ប្រហែលគ្នាថា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ប្រហែលម៉ោង ២០ និង ០០នាទី ខ្លួនកំពុងតែធ្វើការងារនៅក្នុងរោងចក្រមួយកន្លែងឈ្មោះ មហា៣ ដែលស្ថិតនៅតំបន់ឧស្សាហកម្មវត្តរលួន:២ ក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ នៅពេលនោះប្តីរបស់ខ្លួនឈ្មោះ[redacted] កំសាន បានទូរស័ព្ទមកប្រាប់ខ្លួនថា ម៉ូតូដែលគាត់ជិះមកយកខ្លួនត្រូវបានចោរប្លន់បាត់ហើយ បន្ទាប់ពីឮដូចនេះខ្លួនក៏បានសុំខាងរោងចក្រចេញមកមុន ដោយបានហៅម៉ូតូកង់បីជិះទៅរកប្តីនៅកន្លែងកើតហេតុនៅផ្លូវក្រវ៉ាត់ក្រុងទី៣ នៅពេលនោះក៏បានជួបប្តីរបស់ខ្លួនគាត់ក៏



Scanned with CamScanner

បានប្រាប់ខ្លួនថា រូបគាត់បានជិះម៉ូតូចេញពីផ្ទះ នៅភូមិសំបួរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មកយករូបខ្លួនដែលចេញពីធ្វើការថែមម៉ោងនៅរោងចក្រខាងលើ។ លុះនៅពេលដែលគាត់បើកម៉ូតូតាមបណ្ដោយផ្លូវក្រវាត់ក្រុងទី៣ ក្នុងទិសដៅពីកើតទៅលិចចំងាយប្រហែលជា ៥០០ម៉ែត្រ ដល់ស្ពានអាកាស ដែលស្ថិតនៅភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ក៏ស្រាប់តែជនល្មើសមានគ្នាចំនួន ០៦នាក់ ជិះម៉ូតូចំនួន០៣គ្រឿង មិនចាំម៉ាក បានធ្វើសកម្មភាពធាក់ម៉ូតូបណ្ដាលឱ្យដួល ហើយមានគ្នាវាក៏បានយកកម្លូកការពាររបស់វាមកវាយប្ដីខ្លួនរហូតដល់ឈើបបែកខ្ទេច បន្ទាប់មកពួកវាក៏បានលើកម៉ូតូរបស់ប្ដីខ្លួនជិះចេញទៅទិសខាងកើតតែម្ដង។ សម្ភារៈដែលបាត់បង់មានដូចជាម៉ូតូចំនួន០១គ្រឿង ម៉ាក HONDA DREAM C125 ពណ៌ខ្មៅ លេខតួ និងលេខម៉ាស៊ីន 001807 ស៊េរីឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1KC-7815។ ខ្លួនសំណូមពរសុំឱ្យតុលាការ ផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់ និងទាមទារថ្លៃម៉ូតូចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក រួមទាំងសំណងជំងឺចិត្តខាតបង់ពេលវេលាចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក។

ក្រឡាបញ្ជីអានកំណត់ហេតុស្ដាប់ការបំភ្លឺរបស់ជនរងគ្រោះឈ្មោះ [redacted] កំសាន បានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ និងតំណាងអយ្យការប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង ០០នាទី ខ្លួនបានជិះម៉ូតូរបស់ខ្លួនម៉ាក HONDA DREAM C125 លេខតួ និងលេខម៉ាស៊ីន 001807 ពណ៌ខ្មៅ ស៊េរីឆ្នាំ ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1KC-7815 ចេញពីផ្ទះរបស់ខ្លួននៅភូមិសំបួរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ឱ្យខ្លួនជិះទៅយកគាត់ធ្វើការថែមម៉ោងនៅរោងចក្រ មហា៣ ស្ថិតនៅក្នុងតំបន់ឧស្សាហកម្មវត្តឈ្នះ២ ក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ លុះនៅពេលដែលខ្លួនកំពុងតែបើកម៉ូតូពីទិសខាងកើតទៅខាងលិច តាមផ្លូវក្រវាត់ក្រុងទី៣ ខាងកើតស្ពានអាកាស ក៏ស្រាប់តែមានម៉ូតូចំនួន០៣គ្រឿង មានមនុស្សប្រហែលជា០៥នាក់ទៅ ០៧នាក់ ដោយមានម៉ូតូមួយស្ទាក់ពីមុខម៉ូតូរបស់ខ្លួន និងម៉ូតូមួយទៀតជិះចំហៀង ហើយមួយគ្រឿងទៀតនៅពីក្រោយ បន្ទាប់មកម៉ូតូដែលជិះចំហៀងខ្លួនបានធ្វើសកម្មភាពធាក់ម៉ូតូរបស់ខ្លួនបណ្ដាលឱ្យដួល ហើយពួកវាក៏បានយកកម្លូក មកវាយលើក្បាល និងខ្លួនរបស់ខ្លួន បណ្ដាលឱ្យខ្លួនឈឺក្រោកលែងរួច រួចពួកវាក៏បានលើកម៉ូតូរបស់ខ្លួនជិះទៅទិសខាងលិចបាត់តែម្ដង។ បន្ទាប់មកខ្លួនក៏បានទូរស័ព្ទទៅប្រាប់ប្រពន្ធ បន្តិចក្រោយមកគាត់ក៏មកដល់ហើយរូបខ្លួនក៏បានទៅមន្ទីរពេទ្យ ចំណែកប្រពន្ធរបស់ខ្លួនទៅដាក់ពាក្យបណ្ដឹងតែម្ដង។

**សេចក្ដីសន្និដ្ឋានរឿងក្ដីរបស់តំណាងអយ្យការ**

តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា តាមចម្លើយរបស់ជនជាប់ចោទទាំងពីរនាក់ខាងលើ និងស្ដាប់អំណានដើមបណ្ដឹងរដ្ឋប្បវេណី និងភស្តុតាងដែលសមត្ថកិច្ចបានរកឃើញ ឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ប្រាកដមែន ហេតុនេះ តំណាងអយ្យការនៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៨៤ អ.យ.ឃ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

**សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោកស្រីមេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ដោយសារនៅចំពោះមុខអង្គសវនាការកូនក្ដីរបស់ខ្លួនបានឆ្លើយសារភាពនូវអំពើដែលបានប្រព្រឹត្ត និងទទួលស្គាល់កំហុស ហេតុនេះខ្លួនស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាសម្រេចដោយបន្ធូរបន្ថយទោសដល់កូនក្ដីរបស់ខ្លួន។

**សម្ដីចុងក្រោយរបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ [redacted] ចាន់ណាប បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] ហេង បានសំណូមពរសុំតុលាការ ជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីសិទ្ធិឱ្យជនជាប់ចោទ
-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា
-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងរាជធានីភ្នំពេញ**

**យល់ឃើញថា**

ក.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨៣៧ "ឥ" ជ.ជ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចបញ្ជូនទៅជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧០៦ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចខាងកើតស្ពានអាកាស ផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ខ.អង្គហេតុកើតឡើងនៅចំណុចចំណុចខាងកើតស្ពានអាកាស ផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ហេតុនេះជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនៃសាលាដំបូងរាជធានីភ្នំពេញ។

គ.អង្គហេតុកើតឡើងកាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ បើគិតរហូតមកដល់ពេលនេះ មិនទាន់ផុតអាជ្ញាយុកាលនៃបទល្មើសទេ។

ឃ.បើទោះបីជាដើមបណ្តឹងឈ្មោះ [redacted] គន្ធា មិនមានវត្តមាននៅចំពោះមុខអង្គសវនាការក៏ដោយ ប៉ុន្តែតំណាងអយ្យការបានធ្វើការកោះហៅគ្រប់ភាគីពាក់ព័ន្ធឱ្យចូលរួមសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង០៨ និង៣០នាទី ត្រឹមត្រូវរួចរាល់ហើយ ហេតុនេះតុលាការអាចបន្តសវនាការ ដោយកំបាំងមុខដើមបណ្តឹងបាន ។

ង.តាមរបាយការណ៍សំយោគលេខ ០៦០/២៣ រ.ប.ក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោ បានធ្វើការសន្និដ្ឋានថា ឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (ដាក់ប្លន់យកម៉ូតូ) របស់ជនរងគ្រោះឈ្មោះ [redacted] កំសាន នៅចំណុចខាងកើតស្ពានអាកាស ផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ប្រាកដមែន។

ច.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ខ្លួននិងឈ្មោះ [redacted] ហេង បានរង់ចាំឈ្មោះ លី និងបក្ខពួក នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន ស្ថិតនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ២ ដើម្បីប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋដែលជិះតាមផ្លូវ។ បន្តិចក្រោយមកឈ្មោះ លី និងបក្ខពួកបានមកដល់ តែខ្លួនស្គាល់តែឈ្មោះ លី តែម្នាក់ប៉ុណ្ណោះ។ ឈ្មោះ លី និងបក្ខពួក មានគ្នា០៥នាក់ សុទ្ធតែមនុស្សប្រុស បានជិះម៉ូតូចំនួន០៣គ្រឿង បន្ទាប់មកឈ្មោះ លី ក៏បានឱ្យម៉ូតូទៅឈ្មោះ [redacted] ហេង ជាអ្នកបើក ចំណែកខ្លួនជាអ្នកជិះពីក្រោយ ហើយពួកខ្លួនក៏បានជិះម៉ូតូតាមផ្លូវក្រវ៉ាត់ក្រុងទី៣ ខាងកើតស្ពានអាកាស ដែលស្ថិតនៅក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ



Scanned with CamScanner

ខណ្ឌដង្កោ ក៏បានឃើញបុរសម្នាក់ជិះម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125 លេខតួ និងលេខម៉ាស៊ីន 001807 ស៊េរីឆ្នាំ២០២៣ មានផ្លាកលេខភ្នំពេញ 1KC-7815 កំពុងធ្វើដំណើរទិសដៅពីខាងកើតទៅខាងលិច ពេលនោះឈ្មោះ លី និងបក្ខពួកចំនួន០៥នាក់ បានជិះម៉ូតូពីរគ្រឿង ទៅស្ទាក់ពីមុខ និងធាក់ផ្តួលម៉ូតូនោះតែម្តង ចំណែករូបខ្លួនដែលជិះម៉ូតូជាមួយឈ្មោះ មុត ហេង ជាអ្នកចាំស្ទាក់ពីក្រោយ បន្ទាប់មកក្រុមរបស់ឈ្មោះ លី ក៏បានយកមួកការពារវាយលើបុរសនោះរបួសដល់ក្រោកលែងរួច ហើយក៏លើកម៉ូតូនោះជិះទៅត្រង់ទិសដៅខាងលិច ចំណែករូបខ្លួន និងឈ្មោះ [redacted] ហេង ក៏បានបើកម៉ូតូត្រឡប់ក្រោយ ហើយជិះទៅចាំពួកគាត់នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ ឈ្មោះ លី បានជិះម៉ូតូ០១គ្រឿង ជាមួយនឹងគ្នាគាត់ម្នាក់ទៀតមកយកប្រាក់ឱ្យខ្លួនចំនួន ៨០.០០០(ប្រាំបីម៉ឺន)រៀល ចំណែកឈ្មោះ [redacted] ហេង គាត់មិនទាន់បានប្រាក់នោះទេ។ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ [redacted] ហេង រួមទាំងបក្ខពួករបស់ឈ្មោះ លី មានម៉ូតូចំនួន០៣គ្រឿង បានជិះម៉ូតូ បំណងប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋ លុះមកដល់ចំណុចផ្លូវបេតុង ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ក៏ត្រូវបានសមត្ថកិច្ចឃាត់រូបខ្លួន និងឈ្មោះ [redacted] ហេង ទៅអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យដើម្បីសួរនាំតែម្តង ចំណែកបក្ខពួករបស់ឈ្មោះ លី បានជិះម៉ូតូគេចខ្លួនបាត់។

ឆ.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ហេង បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ [redacted] ចាន់លាប បានរង់ចាំឈ្មោះ លី និងបក្ខពួក នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន ស្ថិតនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ២ ដើម្បីប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋដែលជិះតាមផ្លូវ។ បន្តិចក្រោយមកឈ្មោះ លី និងបក្ខពួកបានមកដល់ តែខ្លួនស្គាល់តែឈ្មោះ លី តែម្នាក់ប៉ុណ្ណោះ។ ឈ្មោះ លី និងបក្ខពួក មានគ្នា០៥នាក់ សុទ្ធតែមនុស្សប្រុស បានជិះម៉ូតូចំនួន០៣គ្រឿង បន្ទាប់មកឈ្មោះ លី ក៏បានឱ្យម៉ូតូមកខ្លួនជាអ្នកបើក ចំណែកឈ្មោះ [redacted] ចាន់លាប ជាអ្នកជិះពីក្រោយ ហើយពួកខ្លួនក៏បានជិះម៉ូតូតាមផ្លូវក្រវ៉ាត់ក្រុងទី៣ ខាងកើតស្ពានអាកាស ដែលស្ថិតនៅក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ ក៏បានឃើញបុរសម្នាក់ជិះម៉ូតូមួយគ្រឿងម៉ាក HONDA DREAM C125 លេខតួ និងលេខម៉ាស៊ីន 001807 ស៊េរីឆ្នាំ២០២៣ មានផ្លាកលេខភ្នំពេញ 1KC-7815 កំពុងធ្វើដំណើរទិសដៅពីខាងកើតទៅខាងលិច ពេលនោះឈ្មោះ លី និងបក្ខពួកចំនួន០៥នាក់ បានជិះម៉ូតូពីរគ្រឿង ទៅស្ទាក់ពីមុខ និងធាក់ផ្តួលម៉ូតូនោះតែម្តង ចំណែករូបខ្លួនដែលជិះម៉ូតូជាមួយឈ្មោះ [redacted] ចាន់លាប ជាអ្នកចាំស្ទាក់ពីក្រោយ បន្ទាប់មកក្រុមរបស់ឈ្មោះ លី ក៏បានយកមួកការពារវាយលើបុរសនោះរបួសដល់ក្រោកលែងរួច ហើយក៏លើកម៉ូតូនោះជិះទៅត្រង់ទិសដៅខាងលិច ចំណែករូបខ្លួន និងឈ្មោះ [redacted] ចាន់លាប ក៏បានបើកម៉ូតូត្រឡប់ក្រោយ ហើយជិះទៅចាំពួកគាត់នៅកន្លែងចាក់សំរាមចាស់ក្បែរផ្ទះរបស់ខ្លួន។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៣ ឈ្មោះ លី បានជិះម៉ូតូ០១គ្រឿង ជាមួយនឹងគ្នាគាត់ម្នាក់ទៀត បានឱ្យប្រាក់ទៅឈ្មោះ [redacted] ចាន់លាប ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) រៀល ចំណែកខ្លួនគាត់ថាចាំពេលក្រោយ។ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ ខ្លួន និងឈ្មោះ [redacted] ហេង រួមទាំងបក្ខពួករបស់ឈ្មោះ លី មានម៉ូតូចំនួន០៣គ្រឿង បានជិះម៉ូតូ បំណងប្លន់ម៉ូតូរបស់ប្រជាពលរដ្ឋ លុះមកដល់ចំណុចផ្លូវបេតុង ភូមិទួលពង្រ សង្កាត់ចោមចៅទី១ ក៏ត្រូវបានសមត្ថកិច្ចឃាត់បានរូបខ្លួន និងឈ្មោះ [redacted] ហេង ទៅអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យដើម្បីសួរនាំតែម្តង ចំណែកបក្ខពួករបស់ឈ្មោះ លី បានជិះម៉ូតូគេចខ្លួនបាត់។

ជ.តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គន្ធា បានឆ្លើយថា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ ប្រហែលម៉ោង ២០ និង០០នាទី ខ្លួនកំពុងតែធ្វើការងារនៅក្នុងរោងចក្រមួយកន្លែងឈ្មោះ មហាព ដែលស្ថិតនៅតំបន់ឧស្សាហកម្មវឌ្ឍនៈ២ ក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ពេលនោះប្តីរបស់ខ្លួនឈ្មោះ [redacted] កំសាន បានទូរស័ព្ទមកប្រាប់ខ្លួនថា ម៉ូតូដែលគាត់ជិះមកយកខ្លួនត្រូវបានចោរប្លន់បាត់ហើយ បន្ទាប់ពីឮដូចនេះខ្លួនក៏បានសុំខាងរោងចក្រចេញមកមុន ដោយបានហៅម៉ូតូកង់បីជិះទៅរកប្តីនៅកន្លែងកើតហេតុនៅផ្លូវក្រវ៉ាត់ក្រុងទី៣ នៅពេលនោះក៏បាន



Scanned with CamScanner

ផ្ទះប្ដីរបស់ខ្លួនគាត់ក៏បានប្រាប់ខ្លួនថា រូបគាត់បានជិះម៉ូតូចេញពីផ្ទះ នៅភូមិសំបួរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ មកយករូបខ្លួនដែលចេញពីធ្វើការថែមម៉ោងនៅរោងចក្រខាងលើ។ លុះនៅពេលដែលគាត់បើកម៉ូតូតាមបណ្ដោយផ្លូវក្រវ៉ាត់ក្រុងទី៣ ក្នុងទិសដៅពីកើតទៅលិចចំងាយប្រហែលជា ៥០០ម៉ែត្រ ដល់ស្ពានអាកាស ដែលស្ថិតនៅភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ ក៏ស្រាប់តែជនល្មើសមានគ្នាចំនួន ០៦នាក់ ជិះម៉ូតូចំនួន០៣គ្រឿង មិនចាំម៉ាក បានធ្វើសកម្មភាពឆក់ម៉ូតូបណ្ដាលឱ្យដួល ហើយមានគ្នាវាក៏បានយកម្ជុលការពាររបស់វាមកវាយប្ដីខ្លួនរហូតដល់រងរបួសស្រាលៗ បន្ទាប់មកពួកវាក៏បានលើកម៉ូតូរបស់ប្ដីខ្លួនជិះចេញទៅទិសខាងកើតតែម្ដង។ សម្ភារៈដែលបាត់បង់មានដូចជាម៉ូតូចំនួន០១គ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ លេខតួ និងលេខម៉ាស៊ីន001807 ស៊េរីឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1KC-7815។ ខ្លួនសំណូមពរសុំឱ្យតុលាការជួយស្វែងរកម៉ូតូរបស់ខ្លួនមកវិញ និងផ្ដន្ទាទោសជនល្មើសទៅតាមច្បាប់។

ឈ.តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] កំសាន បានឆ្លើយថា កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ២០ និង០០នាទី ខ្លួនបានជិះម៉ូតូរបស់ខ្លួនម៉ាក HONDA DREAM C125 លេខតួ និងលេខម៉ាស៊ីន 001807 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០២៣ ពាក់ផ្លាកលេខ ភ្នំពេញ 1KC-7815 ចេញពីផ្ទះរបស់ខ្លួននៅភូមិសំបួរ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយប្រពន្ធខ្លួនបានទូរស័ព្ទមកប្រាប់ឱ្យខ្លួនជិះទៅយកគាត់ធ្វើការថែមម៉ោងនៅរោងចក្រ មហាពា ស្ថិតនៅក្នុងតំបន់ឧស្សាហកម្មវត្តស្លែង២ ក្នុងភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ លុះនៅពេលដែលខ្លួនកំពុងតែបើកម៉ូតូពីទិសខាងកើតទៅខាងលិច តាមផ្លូវក្រវ៉ាត់ក្រុងទី៣ ខាងកើតស្ពានអាកាស ក៏ស្រាប់តែមានម៉ូតូចំនួន០៣គ្រឿង មានមនុស្សប្រហែលជា០៥នាក់ ទៅ០៧នាក់ ដោយមានម៉ូតូមួយស្ទាក់ពីមុខម៉ូតូរបស់ខ្លួន និងម៉ូតូមួយទៀតជិះចំហៀង ហើយមួយគ្រឿងទៀតនៅពីក្រោយ បន្ទាប់មកម៉ូតូដែលជិះចំហៀងខ្លួនបានធ្វើសកម្មភាពឆក់ម៉ូតូរបស់ខ្លួនបណ្ដាលឱ្យដួល ហើយពួកវាក៏បានយកម្ជុលមកវាយលើក្បាល និងខ្លួនរបស់ខ្លួន បណ្ដាលឱ្យខ្លួនឈឺក្រោកលែងរួច រួចពួកវាក៏បានលើកម៉ូតូរបស់ខ្លួនជិះទៅទិសខាងលិចបាត់តែម្ដង។ បន្ទាប់មកខ្លួនក៏បានទូរស័ព្ទទៅប្រាប់ប្រពន្ធ បន្តិចក្រោយមកគាត់ក៏មកដល់ហើយរូបខ្លួនក៏បានទៅមន្ទីរពេទ្យ ចំណែកប្រពន្ធរបស់ខ្លួនទៅដាក់ពាក្យបណ្ដឹងតែម្ដង។

ញ.សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងឈ្មោះ [redacted] ហេង ដែលបានធ្វើសកម្មភាពឆក់យកម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] កំសាន បានសម្រេច រួចជិះគេចខ្លួន គឺជាចេតនាទុច្ចរិត ក្នុងបំណងដកហូតយកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃមកធ្វើជាទ្រព្យសម្បត្តិរបស់ខ្លួន។

ដ.តាមចម្លើយជនជាប់ចោទទាំងពីរនាក់ខាងលើ, ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងចម្លើយរបស់ជនរងគ្រោះ ព្រមទាំងរបាយការណ៍សំយោគរបស់សមត្ថកិច្ច និងភស្តុតាងផ្សេងៗទៀត មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងឈ្មោះ [redacted] ហេង ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

ឋ.អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងឈ្មោះ [redacted] ហេង ដែលបានធ្វើសកម្មភាពឆក់ម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] កំសាន និងបានដោះម្ជុលសុវត្ថិភាពវាយជនរងគ្រោះបណ្ដាលឱ្យរងរបួស រួចយកម៉ូតូមួយគ្រឿងម៉ាក ហុងដាឌ្រីម សេ១២៥ ស៊េរីឆ្នាំ២០២៣ ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1KC-7815 បានសម្រេច ហើយនាំគ្នាជិះគេចខ្លួន បើផ្អែកតាមធាតុនីត្យានុកូលស្របទៅនឹងបទ លួចមានស្ថានទម្ងន់ទោស បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-មាត្រា៣៥៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេង



Scanned with CamScanner

ទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

-មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ បានចែងថា អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ ក្នុងករណី អំពើលួចនេះ ប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រើហិង្សា។

ខ.ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៧ឆ្នាំ ជាអនីតិជន មានស្មារតីល្អ មានការយល់ដឹងខុសត្រូវច្បាស់លាស់ ហើយក៏ពុំមានសញ្ញាណណាមួយបញ្ជាក់ថាជននេះមានវិបល្លាសស្មារតីអ្វីដែរ។

ឃ.អំពើដែលជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងឈ្មោះ [redacted] ហេង បានប្រព្រឹត្តធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ជាអំពើដែលច្បាប់ហាមឃាត់ និងតម្រូវឱ្យផ្តន្ទាទោស។

ណ.តាមកំណត់ហេតុស្តាប់ចម្លើយចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គន្ធា បានប្តឹងទាមទារថ្លៃម៉ូតូចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក និងសំណងជំងឺចិត្តខាតបង់ពេលវេលាចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងឈ្មោះ [redacted] ហេង និងសុំឱ្យតុលាការចាត់ការតាមនីតិវិធីច្បាប់។

ត.ពិតមែនថានៅព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យមានការចរាចរសាច់ប្រាក់ជារូបិយប័ណ្ណប្រាក់រៀល ក៏ពិតមែនប៉ុន្តែក៏អាចចរាចរប្រាក់ជារូបិយវត្ថុប្រាក់ដុល្លារអាមេរិកផងដែរ។

ថ.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា រក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ៤៤៨៤ អ.យ.ឃ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ការស្នើសុំតុលាការនឹងលើកយកមកពិចារណា។

ទ.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តី ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

ធ.ជនជាប់ចោទឈ្មោះ [redacted] ចាន់លាប បានសំណូមពរសូមឱ្យស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

ន.ជនជាប់ចោទឈ្មោះ [redacted] ហេង បានសំណូមពរសូមឱ្យលោកចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ការស្នើសុំនេះតុលាការនឹងលើកយកមកធ្វើការពិចារណា។

មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ មុត ហេង ភេទប្រុស អាយុ១៧ឆ្នាំ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចខាងកើតស្ពានអាកាស ផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោសជនជាប់ចោទ ៖

ក.ឈ្មោះ [redacted] ចាន់លាប ភេទប្រុស អាយុ១៦ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ។

ខ.ឈ្មោះ [redacted] ហេង ភេទប្រុស អាយុ១៧ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចខាងកើតស្ពានអាកាស ផ្លូវបេតុងក្រវ៉ាត់ក្រុងទី៣ ភូមិទឹកថ្លា សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ

Scanned with CamScanner

រាជធានីភ្នំពេញ កាលពីថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងជនជាប់ចោទឈ្មោះ [redacted] ហេង សងថ្លៃម្ហូបចំនួន៨.០០០.០០០ រៀល (ប្រាំបីលានរៀល) ឱ្យទៅឈ្មោះ [redacted] គន្ធា ការទាមទារលើសពីនេះត្រូវច្រានចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង០៨ និង៣០នាទីព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់លាប និងឈ្មោះ [redacted] ហេង និងកំបាំងមុខដើមបណ្តឹងឈ្មោះ [redacted] គន្ធា និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ១៤ និង៣០នាទី។

ទុកសិទ្ធិទាស់ និងប្តឹងឧទ្ធរណ៍តាមច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃព្រហស្បតិ៍ ១២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

Scanned with CamScanner